（カンボジア語版）

# ធានារ៉ាប់រងសង្គមសម្រាប់មនុស្សគ្រប់គ្នា!!

## ជាដំបូង តើធានារ៉ាប់រងសង្គមគឺជាអ្វីអោយប្រាកដ?

◆ ហានិភ័យគឺជាអ្វីដែលនឹងកើតឡើងចំពោះអ្នក ដរាបណាអ្នកនៅរស់។

ជំងឺ





ការរងរបួស



ភាពចាស់ជរា



ពិការភាព

◆ ហានិភ័យមានការពិបាកណាស់ក្នុងការព្យាករណ៍សម្រាប់បុគ្គល។ គ្មាននរណាម្នាក់ដឹងច្បាស់ថានៅពេលណាឬថាតើពួកគេនឹងឈឺឬរងរបួសឬអត់ ពួកគេនឹងរស់នៅរហូតដល់រយៈពេលប៉ុន្មាន ឬថាតើពួកគេនឹងរងគ្រោះដោយសារពិការភាពឬអត់នោះទេ។

◆ លើសពីនេះទៅទៀត មានស្ថានភាពសង្គមនិងសេដ្ឋកិច្ចមួយចំនួនដែលមិនអាចទស្សន៍ទាយបាន។ ការត្រៀមលក្ខណៈចំពោះស្ថានភាពទាំងនោះសំរាប់បុគ្គលម្នាក់ៗ គឺនៅមានកម្រិត ហើយ **ការធានារ៉ាប់រងសង្គម** គឺជា គ្រោងការណ៍ដើម្បីគាំទ្រនិងជួយគ្នាទៅវិញទៅមកក្នុងនាមសង្គមទាំងមូល។

## ធានារ៉ាប់រងសុខភាពសាធារណៈ និងការធានារ៉ាប់រងសោធននិវត្តន៍

◆ ដោយការបង់ការរួមចំណែកធានារ៉ាប់រង តាមរយៈប្រព័ន្ធធានារ៉ាប់រងសង្គម អ្នកអាចទទួលបានអត្ថប្រយោជន៍ក្នុងករណីដែលអ្នកពិតជាជួបការលំបាកដែលមិនបានរំពឹងទុក។

◆ ឧទាហរណ៍៖

・នៅពេលអ្នកឈឺឬរងរបួស **ធានារ៉ាប់រងសុខភាព** នឹងជួយឱ្យអ្នកទទួលបានសេវាសុខភាពក្នុងតម្លៃព្យាបាលទាបនៅស្ថាប័នសុខភាពណាមួយ ។

・ប្រសិនបើអ្នកទទួលរងគ្រោះពីពិការភាព ឬនៅពេលដែលអ្នកចាស់ហើយឈានដល់អាយុជាក់លាក់មួយ **ការធានារ៉ាប់រងសោធននិវត្តន៍** នឹងជួយឱ្យអ្នកទទួលបានអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ជាប្រចាំ។

ការធានារ៉ាប់រងសង្គមគឺជាប្រព័ន្ធសកល ហើយជាគោលការណ៍ទូទៅ អ្នកដែលរស់នៅក្នុងប្រទេសជប៉ុនដែលរួមទាំងជនជាតិជប៉ុននិងមិនមែនជនជាតិជប៉ុន**ដោយមិនគិតពីសញ្ជាតិ** ត្រូវចុះឈ្មោះនៅក្នុងនោះ។

ひと、くらし、みらいのために
厚生労働省
Ministry of Health, Labour and Welfare

日本年金機構
Japan Pension Service